ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍មាត់ខ្លា

## សម្រាប់រយៈពេល ៣ ឆ្នាំ
## (២០១៧ - ២០១៩)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | មាត់ខ្លា |
| ភូមិ | ៖ | មាត់ខ្លា |
| ឃុំ | ៖ | អន្លង់សំណ |
| ស្រុក | ៖ | ស្រុកជីក្រែង |
| ខេត្ត | ៖ | សៀមរាប |

ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ
# សហគមន៍មាត់ខ្លា
## សម្រាប់រយៈពេល ៣ ឆ្នាំ
## (២០១៧ - ២០១៩)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | មាត់ខ្លា |
| ភូមិ | ៖ | មាត់ខ្លា |
| ឃុំ | ៖ | អន្លង់សំណ |
| ស្រុក | ៖ | ស្រុកជីក្រែង |
| ខេត្ត | ៖ | សៀមរាប |

**ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១៦**

# មាតិកា


១.ស្ថានភាពទូទៅ ........................................ ៤
២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........................................ ៥
ក.ប្រជាពលរដ្ឋ ........................................ ៥
ខ. មុខរបរ ........................................ ៥
៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ........................................ ៦
ក. ទីតាំង ........................................ ៦
ខ. ដែននេសាទ ........................................ ៦
ខ.១.ព្រៃក ........................................ ៦
ខ.២.ត្រពាំង ........................................ ៧
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........................................ ៨
ឃ. ធនធានជលផល ........................................ ៩
១.ប្រភេទត្រី ........................................ ៩
២.ប្រភេទវារីសត្វ ........................................ ៩
៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ........................................ ១០
៤.ការធ្វើនេសាទ ........................................ ១០
ក.អ្នកនេសាទ ........................................ ១០
ខ.ឧបករណ៍នេសាទ ........................................ ១១
គ.ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ ........................................ ១២
៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ១២
ក.ទស្សនៈវិស័យ ........................................ ១២
ខ.គោលបំណង ........................................ ១២
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ១៣
គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........................................ ១៤
គ.២. ផែនការកែលម្អដែននេសាទ ........................................ ១៦
គ.៣. ផែនការរៀបចំកន្លែងអភិរក្ស ........................................ ១៥
គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ........................................ ១៦
គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........................................ ១៧
គ.៦. ផែនការថវិកាទ្រទ្រង់សម្រាប់ការអភិវឌ្ឍន៍សហគមន៍ ........................................ ១៨
គ.៧.ផែនការផ្សេងៗ ........................................ ១៩
គ.៧.១.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ ........................................ ១៩
គ.៧.២. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ........................................ ២០
គ.៧.៣. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ ........................................ ២០

គ.៧.៤.ផែនការជួសជុលស្នាក់ការសហគមន៍ ........................................................................ ២១
ឃ. យុទ្ធសាស្ត្រ ............................................................................................................ ២១

៦.ឧបសម្ពន្ធ
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៧-២០១៩ .................. ២៣
ឧបសម្ពន្ធ ៖ តារាងកម្មវិធីការងារឆ្នាំ២០១៧-២០១៩ ..................................................... ២៧

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មាត់ខ្លា

## ១- ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឲ្យស្របជាមួយគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធចតុកោណរបស់រាជរដ្ឋាភិបាលដែលផ្ដោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ឱ្យចូលរួមចូលរួមគ្រប់គ្រងធនធានជលផលនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលបានប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ កន្លងមក ភូមិមាត់ខ្លាត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបជំនាញជលផល និងសហការពីអាជ្ញាធរដែនដី ។ ដូចនេះសហគមន៍នេសាទមាត់ខ្លា ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១ នៅថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០០៧ ដែលបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដោយបានអនុវត្តចាប់ពីឆ្នាំ ២០០៨ ដល់ ២០១០ ព្រមទាំងត្រូវបានក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ សហគមន៍នេសាទមាត់ខ្លា ត្រូវបានរៀបចំបោះឆ្នោតឡើងវិញលើកទី២ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៥ ព្រមទាំងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មាត់ខ្លានេះ នឹងបច្ចុប្បន្នភាព និងរៀបចំលើកទី ២ នៅថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៦ ដោយមានចូលរួមពីសមាជិកគណៈកម្មសហគមន៍នេសាទ ប្រជាពលរដ្ឋ មេភូមិមាត់ខ្លា ក្រុមប្រឹក្សា ជាពិសេសបានការគាំទ្របច្ចេកទេស និងថវិកាពីរដ្ឋបាលជលផលថ្នាក់កណ្ដាល និងសម្របសម្រួលដោយខណ្ឌរដ្ឋបាលជលផលសៀម ។

គណៈកម្មការសហគមន៍នេសាទត្រូវបានបោះឆ្នោតចំនួន ០២ អណ្ណត្តិ រហូតមកដល់ពេលបច្ចុប្បន្ន ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ ។ ទន្ទឹមនឹងនេះ គណៈកម្មសហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្ដុះបណ្ដាល សិក្ខាសាលា ប្រជុំបណ្ដាញការងារ និងទស្សនកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ ។

ដូច្នេះ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មាត់ខ្លា បានធ្វើការកែសម្រួលសកម្មភាពសំខាន់ៗខ្លះ និងថវិកាដែលគ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងអភិរក្ស នេសាទសហគមន៍ តំបន់អភិរក្ស ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយចីរភាព និងសមធម៌។

## ២-អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំនេះមានចំនួន ១៦ ភូមិ ប្រជាពលរដ្ឋសរុបចំនួន ២៨១៤ គ្រួសារ ។ ដោយឡែកសហគមន៍នេសាទមាត់ខ្លា គ្រប់ដណ្ដប់តែមួយភូមិដែលហៅថា ភូមិមាត់ខ្លា ដោយមានប្រជាពលរដ្ឋសរុបចំនួន ២៩៣ គ្រួសារ ក្នុងនោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ៣៨ នាក់ ។ ដូច្នេះ ចំនួនគ្រួសារដែលចូលជាសមាជិកសហគមន៍នេសាទមានតែចំនួន ២៤៥ គ្រួសារ ក្នុងនោះ មនុស្សដែលជាសមាជិកសហគមន៍នេសាទចំនួន ៦៣៧ នាក់ ។

សហគមន៍នេសាទមាត់ខ្លា មានប្រជាពលរដ្ឋមនុស្សសរុបចំនួន ១២៩៦ នាក់ ក្នុងនោះស្ត្រីមានចំនួន ៦៦៨ នាក់ ដែលប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទភូមិមាត់ខ្លា ជាជនជាតិខ្មែរ ហើយគោរពព្រះពុទ្ធសាសនា ដែលមានស្ថានភាពដូចជា៖

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងឃុំអន្លង់សំណរបានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ ១ មានចំនួន ១ គ្រួសារ និងស្ថានភាពក្រីក្រ ២ មានចំនួន ៣១ គ្រួសារ ដែលសរុបចំនួន ៣២ គ្រួសារ ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៣៥ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ៧ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានប្រុស ១៥ នាក់ ក្នុងនោះស្ត្រីមានចំនួន ០៩ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ ៧ នាក់ ក្នុងនោះកុមារីមានចំនួន ០២ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៨ នាក់ក្នុងនោះស្ត្រីមានចំនួន ០៥ នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ០៥ នាក់ ក្នុងនោះស្ត្រីមានចំនួន ០២ នាក់
- សាលារៀនបឋមសិក្សាសុខាល័យមានចំនួនមួយខ្នង ដែលមាន ០២ បន្ទប់ មានសិស្សសរុបចំនួន ២១១ នាក់ ក្នុងនោះកុមារីមានចំនួន ១១១ នាក់
- ចំនួនគ្រួសារដែលកើតមេរោគអេដ៍មានចំនួន ០១ នាក់
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំអន្លង់សំណរ នៅក្នុងសហគមន៍នេសាទភូមិមាត់ខ្លាបានបង្ហាញថា ១៣៥ នាក់ដែលមិនចេះអក្សរ ក្នុងស្ត្រីចំនួន ៩៧ នាក់ ។

## ខ.សេដ្ឋកិច្ចសង្គម

តាមរបាយការណ៍ និងឯកសារព័ត៌មានឃុំឆ្នាំ ២០១៦ បានបញ្ជាក់ថា នៅក្នុងសហគមន៍មាត់ខ្លា មានប្រពលរដ្ឋសរុបចំនួន ២៩៣ គ្រួសារ ក្នុងនោះមានប្រពលរដ្ឋប្រហែល ៩៤ ភាគរយ ដែលស្មើនឹង ២៧៥ គ្រួសារ បានពឹងផ្អែកលើការនេសាទ ក្រៅពីនេះ លក់ដូរ ជាងធ្វើមាស៊ីនកាណូត រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជា ផ្តល់ចំណីត្រី លក់ដូរ និងកែច្នៃផលត្រីជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅងក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានការរីកចំរើន ។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទមាត់ខ្លា ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមាន៖

**ខ.១.អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារ ដូចជា៖**

- អ្នកដែលមានមុខរបរពឹងផ្អែកលើការនេសាទស្ទើតែទាំងស្រុកមានចំនួន ១០៩ គ្រួសារ

**ខ.២.អ្នកដែលមានមុខរបរនេសាទ និងធ្វើអាជីវកម្មផ្សេងៗដូចជា៖**

- ប្រមូលទិញ និងលក់ជលត្រី និងនេសាទមានចំនួន ៥ គ្រួសារ
- ធ្វើជាអ្នកនេសាទ និង អ្នកចិញ្ចឹមត្រីចំនួន ៨១ គ្រួសារ (ត្រីរ៉ស ត្រីប្រា និងត្រីអណ្តែង)
- ធ្វើជាអ្នកនេសាទ និងចិញ្ចឹមសត្វលក្ខណៈគ្រួសារ មានប្រហែល ១៥ គ្រួសារ

- អ្នកកែច្នៃផលត្រី និងនេសាទដូចជា៖ ធ្វើផ្អក ប្រហុក និងត្រីឆ្អើរ មានចំនួន ២៧ គ្រួសារ
- កម្មករ និងនេសាទមានចំនួន ២២ គ្រួសារ
- ជាងធ្វើទូក និងនេសាទមានចំនួន ០៩ គ្រួសារ
- រត់ទូកដរ និងនេសាទ មានចំនួន ០៣ គ្រួសារ
- គ្រូបង្រៀន និងនេសាទ ០៤ គ្រួសារ

**ខ.៣.អ្នកដែលមានមុខរបរអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ**

- អ្នកលក់ដូរ ១៦ គ្រួសារ
- ជាងធ្វើមាស៊ីនកាណូត ០២ គ្រួសារ

## ៣- កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក.ទីតាំង

សហគមន៍នេសាទមាត់ខ្លាមានទីតាំងស្ថិតក្នុងភូមិមាត់ខ្លា ដែលជាដែននេសាទសាធារណៈរបស់រដ្ឋដែលពីអតីតកាលគឺជាឡូត៍នេសាទលេខ ០៦ និងលេខ ០៧ នៃដែននេសាបទឹកសាបក្នុងខេត្តសៀមរាប ។ កន្លែងនេសាទសហគមន៍មាត់ខ្លាមានទំហំ ៤,៦៦២ ហិកតា ហើយមានកន្លែងអភិរក្សពូជត្រីសំខាន់ៗចំនួន ០២ កន្លែងគឺ អន្លង់កោះពេជ្រយំមានទំហំប្រហែល ៥ ហិចតា និងព្រៃកទួលស្រោងមានទំហំប្រហែល ៩៦២ ហិចតា។ ទីតាំងទាំងនេះត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ដែលក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ ដូចនេះ សហគមន៍នេសាទមាត់ខ្លាមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹង ជ្រោយកោះពេជយំ
- ខាងត្បូងទល់នឹង ភូមិពេជ្រចក្រី (ឡូត៍នេសាទ ៥ )ស្តើងឃុំពាមប៉ាង
- ខាងកើតទល់នឹង ភូមិ ចុងស្តើងឃុំពាមប៉ាង
- ខាងលិចទល់នឹង ទល់ទន្លេសាប ។

### ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទមាត់ខ្លា មានវិសាលភាពនៅក្នុងទន្លេបឹងទន្លេសាបដែលគ្រប់ដណ្ដប់លើកន្លែងនេសាទបឹងទន្លេសាប កន្លែងអភិរក្សពូជត្រី ព្រៃក គ្រពាំង និងអន្លង់សំខាន់ៗ មួយចំនួនដូចជា៖

**ខ.១ ព្រៃក**

| ល.រ | ឈ្មោះព្រៃក | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | ព្រៃកអន្លង់ឆ្កោរ | ៥០,៨១ | ខែ ០៨ - ខែ ០៣ |
| ២ | ព្រៃកកោះគគី | ៥០ | ខែ ១០ - ខែ ០៣ |
| ៣ | ព្រៃកមាត់ខ្លា | ៣៣,១៩ | ខែ ០៨ - ខែ ១០ |
| ៤ | ព្រៃកអន្លង់អញ្ចាញ | ១៧ | ខែ ០៩ - ខែ ០៣ |
| ៥ | ព្រៃកទល់កំព្រាម | ១៣ | ខែ ០៨ - ខែ ០៤ |
| ៦ | ព្រៃកអន្លង់ញី | ១០,៨០ | ខែ ០៨ - ខែ ០៤ |
| ៧ | ព្រៃកកោះពេជ្រយំ | ៩,៦១ | ខែ ០៩ - ខែ ០៣ |
| ៨ | ព្រៃកខ្វែងទង | ៨,៤៧ | ខែ ០៩ - ខែ ០៣ |
| ៩ | ព្រៃកយពេជចក្រី | ៣,៣០ | ខែ ០៨ - ខែ ១០ |

| | | | |
|---|---|---|---|
| ១០ | ព្រៃកខ្វែងសារាយ | ៣,៣០ | ខែ ០៨ - ខែ ១០ |
| ១១ | ព្រៃកចង្កៀត្លូវ | ២,៥០ | ខែ ០៨ - ខែ ០៣ |
| ១២ | ព្រៃករហាលរាំងជ្រំ | ២,១០ | ខែ ០៩ - ខែ ០៣ |
| ១៣ | ព្រៃកទួលស្រោង | ១,៩០ | ខែ ០៩ - ខែ ១០ |
| ១៤ | ព្រៃកខ្វែងទល់រាំងជ្រំ | ១,៨០ | ខែ ០៩ - ខែ ០៣ |
| ១៥ | ព្រៃកលកខាងត្បូង | ១,៨០ | ខែ ០៨ - ខែ ០២ |
| ១៦ | ព្រៃកមហាច | ១,៧០ | ខែ ០៩ - ខែ ០៣ |
| ១៧ | ព្រៃកអន្លង់កាម៉ាល់ | ១,៦០ | ខែ ០៩ - ខែ ០៣ |
| ១៨ | ព្រៃកបឹងវែង | ១,៥០ | ខែ ០៩ - ខែ ០៣ |
| ១៩ | ព្រៃកផ្លូវទូក | ១,៥០ | ខែ ០៩ - ខែ ០៣ |
| សរុបទំហំគិតជាហិចតា | | **២១៥,៨៧** | |

**ខ.២ ត្រពាំង**

| ល.រ | ឈ្មោះត្រពាំង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | ត្រពាំងកំពឹងប្រប៉ុស | ៤,៨០ | ខែ ០៨ - ខែ ១០ |
| ២ | ត្រពាំងបឹងលួង | ៣,៩០ | ខែ ០៨ - ខែ ១០ |
| ៣ | ត្រពាំងផ្សោត | ៣,៨០ | ខែ ០៨ - ខែ ១០ |
| ៤ | ត្រពាំងកោះរាំងសៀម | ៣,៥០ | ខែ ០៨ - ខែ ១០ |
| ៥ | ត្រពាំងតាចូច | ២,៥០ | ខែ ០៨ - ខែ ១០ |
| ៦ | ត្រពាំងខ្វែងធានរាច | ២,១០ | ខែ ០៨ - ខែ ១០ |
| ៧ | ត្រពាំងក្រធាយ | ២,១០ | ខែ ០៨ - ខែ ១០ |
| ៨ | ត្រពាំងប្រលិត | ១,៥០ | ខែ ០៨ - ខែ ១០ |
| ៩ | ត្រពាំងចក | ១,៤០ | ខែ ០៨ - ខែ ១០ |
| ១០ | ត្រពាំងភ្លោះ | ១,៤០ | ខែ ០៨ - ខែ ១០ |
| **សរុប** | | **២៥** | |

កន្លែងនេសាទសហគមន៍មាត់ខ្លា មានព្រៃកចំនួន ១៩ ព្រៃក ដែលមានទំហំប្រមាណ **២១៥,៨៧** ហិចតា ត្រពាំងមានចំនួន ១០ ត្រពាំងដែលមានទំហំប្រមាណ **២៥ ហិកតា** ព្រៃលិចទឹកមានទំហំសរុប ១,២៤៧ ហិកតា តំបន់វាលស្មៅមានទំហំប្រមាណ ២៦ ហិកតា និងផ្ទៃដែននេសាទដែលជាបឹង អូរ ព្រៃក និងត្រពាំងរួមទាំងដែនសម្រាប់ប្រជាពលរដ្ឋដែលមិនបង្ហាញលំអិតក្នុងចំនុច ខ និង គ គឺជាកន្លែងនេសាទបឹងទន្លេសាបក្នុងសហគមន៍មានទំហំសរុប ២១៨១,១៣ ហិកតា ។

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍នេសាទមាត់ខ្លាបានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែង គឺ អន្លង់កោះពជ្រយំ និងថ្លុលស្រោងដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការ

គ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទមាត់ខ្លា ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរមានដូចខាងក្រោម៖

| ល.រ | ឈ្មោះអន្លង់ | ទំហំគិតជាហត | ការអភិរក្ស |
|---|---|---|---|
| ១ | អន្លង់កោះពេជយំ | ៥ | កន្លែងអភិរក្សត្រីមេពូជ |
| ២ | ថ្លុលស្រោង | ៩៦២ | កន្លែងអភិរក្សត្រីមេពូជ |
| សរុប | ៩៦៧ | | |

**ឃ.ធនធានជលផល**

**១.ប្រភេទត្រី៖**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយខ្សែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍មាត់ខ្លា បានឲ្យដឹងថាពេលបច្ចុប្បន្ន ធនធានជលផលបានថយចុះជាពិសេសក្នុងឆ្នាំ ២០១៥ ដោយសារមានការប្រែប្រួលអាកាសធាតុដែលធ្វើឱ្យបឹង និងព្រែករីងរាក់ ហើយធ្វើឲ្យប្រភេទត្រីមេពូជត្រូវបាននេសាទយកស្ទើរតែទាំងអស់ ។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ និងសមាជិកសហគមន៍ ធនធានជលផលក្នុងសហគមន៍នេសាទមាត់ខ្លាមានដូចជា៖

**ឃ.១.ប្រភេទត្រី:**

ក្នុងសហគមន៍នេសាទមាត់ខ្លាមានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍គុក ត្រីក្អែក ត្រីគ្រំ ត្រីចិន ត្រីឆ្ពិន ត្រីកន្ត្រប់ ត្រីប្រម៉ា ត្រីក្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទឹង ត្រីគល់រាំង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្កោក ត្រីកញ្ចុះក្តោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំភ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្កៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីពូលូង ត្រីស្រកាក្តាម ត្រីកំភ្លៀវ ត្រីខ្មាន់ ត្រីគ្រុំ ត្រីដៀប ត្រីចង្វាមូល ត្រីក្លាំងហាយ ត្រីក្អែក ត្រីលិញ ត្រីឆ្លាំង ។ល។

**ឃ.២.ប្រភេទវារីសត្វ:**

ក្នុងសហគមន៍នេសាទមាត់ខ្លា មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់កង្កែប ហ៊ីង គីង្គក់ អន្ទង់ ក្តាមទូក កន្ទេះឡង់ ក្រពើត្រី អន្សង់ គេ សត្វស្វាក្រុះ សំពោច ។ល។

**ឃ.៣.ប្រភេទបក្សី:**

ក្នុងសហគមន៍នេសាទមាត់ខ្លា មានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វគ្រៀល សត្វទោម សត្វទុង សត្វប្រវឹកសត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វទុង សត្វស្មោញ សត្វសេក សត្វលលកសត្វចាប សត្វត្រយង សត្វរនាលខ្យង សត្វត្រដក់ សត្វក្រសា សត្វកំពីងដូង។ល។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ:**

ក្នុងសហគមន៍នេសាទមាត់ខ្លា មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើមតាអូរដើមអញ្ចាញ ដើមថ្នាន់ ដើមកន្សែង ដើមបន្លាយូន ដើមស្នាចទឹក ដើមកណ្តាប់ចង្អេរ ដើមរំដេញ ដើមបន្លាស្អិត ដើមច្រកែង ។ល។

**៤-ការធ្វើនេសាទ:**

នេសាទជាមុខរបរចាំបាច់សម្រាប់ការចិញ្ចឹមជីវិតរបស់សហគន៍នេសាទមាត់ខ្លា និងផលិតផលត្រីត្រូវបានធ្វើអាជីវកម្មក្នុងតំបន់ផ្ទាល់ដើម្បីរកចំណូល ហើយនាំបានចេញមកទីក្រុងក្នុងប្រទេស ព្រមទាំងបានធ្វើពាណិជ្ជកម្មក្រៅប្រទេសទៀតផង។ ពេលបច្ចុប្បន្ន ប្រជាពលរដ្ឋទាំងអស់ក្នុងសហនេះបានផ្តោតលើការនេសាទ ដោយបានប្រើប្រាស់

ឧបករណ៍លក្ខណៈគ្រួសារ ក្នុងការទាញយកផលនេសាទ ប៉ុន្តែការនេសាទរបស់សមាជិកសហគមន៍ និងអ្នកខាងក្រៅត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ ជាពិសេសផែនការគ្រប់គ្រងរបស់សហគមន៍ដែលបានរៀបចំសម្រាប់ឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១០ ។ ទោះបីជាយ៉ាងនេះក្តី នៅមានជនល្មើសខ្លះ បានប្រើប្រាស់ឧបករណ៍ខុសច្បាប់នៅលើកន្លែងនេសាទសហគមន៍មាត់ខ្លា ជាពិសេស នៅក្នុងកំឡុងឆ្នាំ ២០១៥ ដែលមានបញ្ហាគ្រោះរាំងស្ងួតបានធ្វើឲ្យបឹង ព្រែក និងត្រពាំងបារីងរាក់ ហើយប្រភេទត្រីមេពូជបាននេសាទដោយជនល្មើស ។

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងសហគមន៍មាត់ខ្លា បានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍មាត់ខ្លាមានដូចខាងក្រោម៖

### ៤.ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១២៧ គ្រួសារ មានចំនួន ៥០១ នាក់ ក្នុងនោះស្ត្រីមានចំនួន ២៥៤ នាក់ ។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មាត់ខ្លា មានចំនួន ១៦៦ គ្រួសារដែលមានមនុស្សសរុបចំនួន ៦៨៩ នាក់ ក្នុងនោះស្ត្រីមានចំនួន ៣០៥ នាក់ ។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍មាត់ខ្លាមានប្រហែល ៣៦៧ នាក់ ក្នុង១ឆ្នាំ ។

### ៤.ខ.ឧបករណ៍នេសាទ

នៅរដូវបើកនេសាទប្រជាជននៅក្នុងសហគមន៍នេសាទមាត់ខ្លា និងអ្នកខាងក្រៅតែងតែធ្វើនេសាទដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារដូចជា៖ លប មង សន្ទូច ។ល។ ដូចនេះផងដែរ សមាជិកនិងគណៈកម្មការសហគមន៍នសាទមាត់ខ្លា បានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍នេសាទដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង ជាពិសេស សមាជិក និងគណៈកម្មការសហគមន៍នសាទមាត់ខ្លា ទាមទារសមត្ថកិច្ចជំនាញជលផលធ្វើការផ្សព្វផ្សាយច្រើនដងដល់ប្រជាពលរដ្ឋក្នុសហគមន៍ និងអ្នកនសាទខាងក្រៅលើប្រភេទឧបករណ៍នេសាទដែលហាមឃាត់ដូចជា៖ ឧបករណ៍ឆក់ត្រីអ៊ុយស្បៃមុង ។ល។

ឧបករណ៍នេសាទ និងទូកការល្បាតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុង សហគមន៍មាត់ខ្លាដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ២០០ម x១,៥ម x០,០៣៥ម | ពីខែ ០១ ដល់ ខែ ១២ |
| ២ | អួនអូសដោយដៃ | ម៉ែត្រ | ៥០ម x ២,៥ម x០,០៣៥ម | ពីខែ ០៣ ដល់ ខែ ០៦ |
| ៣ | សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ពេញ១ឆ្នាំ |
| ៤ | លប | លប | ៥៥ | ខែ ០៣ ដល់ ខែ ០៦ |
| ៥ | ដាក់ឡើ | ឡើ | ៦៥ | ខែ ០៨ ដល់ ខែ ០៣ |
| ៦ | ដាក់លាន់ | លាន់ | ៦៥ | ខែ ០១ ដល់ ខែ ០២ |
| ៧ | កន្ទុំកំពឹស | ដុំ | ១០០ ដុំ | ខែ ០៧ ដល់ ខែ ០៣ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន HONDA | ៤០ | ៤០០ | ៦ និង ១៦០ |
| កាណូតម៉ាស៊ីន Hynota | ៥០ | ៥០០ | ៦ និង១៨០ |
| កាណូត Cava | ៣០ | ៣០០ | ១៦០ |
| ទូកអុំ ឬទូកចែវ | ១៥០ | ១០០ | |

ឧបករណ៏នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៏នេសាទ

| ប្រភេទឧបករណ៏ | ឯកតា | ទំហំ/ប្រវែង/គ្រួសារ | រដូវនេសាទ |
|---|---|---|---|
| មងរាយ | ម៉ែត្រ | ១០០ម x១,៥ម x០,០៣៥ម | ពីខែ០១ ដល់ ខែ ១២ |
| សន្ទូចរនង | ផ្លែ | ២០០ ផ្លែ | ខែ ០៨ ដល់ ខែ ០៣ |
| លប | លប | ៣០ លប | ខែ ០៣ ដល់ ខែ ០៦ |
| ដាក់ឡើ | ឡើ | ៣០ ឡើ | ខែ ០៨ ដល់ ខែ ០៣ |
| ដាក់លាន់ | លាន់ | ៣០ លាន់ | ខែ ០១ ដល់ ខែ ០២ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន HONDA | ២៥ | ៤០០ | ៦ និង ១៦០ |
| កាណូតម៉ាស៊ីន Hynota | ៣០ | ៥០០ | ៦ និង១៨០ |
| កាណូត Cava | ១៥ | ៣០០ | ១៦០ |
| ទូកអុំ ឬទូកចែវ | ១៣១ | ១០០ | |

**គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៥៥០០ | ៧៥០០ | ១៣ ០០០ |
| ក្តាម ខ្យង ខ្ចៅ និងលៀស | ៥០០ | ៦៥០ | ១១៥០ |
| អន្ទង់ | ៦៥០ | ៧៥០ | ១៤០០ |
| កំពឹស | ២៥០ | ៣៥០ | ៦០០ |
| សរុប | ៦៩០០ | ៩២៥០ | ១៦១៥០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទមាត់ខ្លា មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនន់ និងព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ ចំរុះដោយមានការចូលរួម
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

#### គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ និងរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទដោយធ្វើយ៉ាងណាមិនឲ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

| ល.រ | ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | |
|---|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង/គ្រួសារ | ចំនួនគ្រួសារ |
| ១ | បឹងទន្លេសាបក្នុងសហគមន៍ | ខែ១០-ខែ៦ | មងរាយ កន្សៀ | ២០០ម | ៧០ |
| | | ខែ១០-ខែ៣ | សន្ទូចរនង | ៥០០ផ្លែ | ២០ |
| | | ខែ២-ខែ៦ | មងអូសដៃ | ១០០ | ៥០ |
| ២ | ព្រែកអន្លង់ឆ្តោរ | ខែ២-ខែ៦ | លបកំភ្លាញ | ១៥ លប | ៣០ |
| | | ខែ១០-ខែ៦ | លាន់ | ៥០ លាន់ | ៥៥ |
| ៣ | ព្រែកកោះគគី | ខែ២-ខែ៦ | មងរាយ | ២០០ម | ៥០ |
| | | ខែ២-ខែ៦ | លបកំភ្លាញ | ១៥ លប | ២០ |
| ៤ | ព្រែកមាត់ខ្លា | ខែ១០-ខែ៦ | មងរាយ | ២០០ម | ៧០ |
| | | ខែ២-ខែ៦ | លបកំភ្លាញ | ១៥ លប | ២៥ |
| ៥ | ព្រែកអន្លង់អញ្ចាញ | ខែ២-ខែ៦ | លបកំភ្លាញ | ១៥លប | ៣០ |
| | | ខែ១០-ខែ៦ | លាន់ | ៥០លាន់ | ២០ |
| ៦ | ព្រែកទល់កំព្រាម | ខែ១០-ខែ៦ | មងរាយ | ២០០ម | ៥០ |
| | | ខែ២-ខែ៦ | លបកំភ្លាញ | ១៥ លប | ៣០ |
| ៧ | ព្រែកអន្លង់ញី | ខែ២-ខែ៦ | មងអូសដៃ | ៥០ម | ៥០ |
| | | ខែ១០-ខែ៦ | មងរាយ | ២០០ម | ៣០ |
| ៨ | ព្រែកកោះពេជ្រយំ | ខែ២-ខែ៦ | លបកំភ្លាញ | ១៥ លប | ៤០ |
| | | ខែ១០-ខែ៦ | លាន់ | ៥០លាន់ | ៧០ |
| | | ខែ១០-ខែ៦ | មងរាយ | ២០០ម | ៦០ |

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ២០០ម x១,៥ម x០,០៣៥ម | ពីខែ ០១ ដល់ ខែ ១២ |
| ២ | អួនអូសដោយដៃ | ម៉ែត្រ | ៥០ម x ២,៥ម x០,០៣៥ម | ពីខែ ០៣ ដល់ ខែ ០៦ |
| ៣ | សន្ទូចរនង | ផ្លែ | ៥០០ ផ្លែ | ពេញ១ឆ្នាំ |
| ៤ | លបកំភ្លាញ | លប | ៥៥ | ខែ ០៣ ដល់ ខែ ០៦ |
| ៥ | ដាក់ឡើ | ឡើ | ៦៥ | ខែ ០៨ ដល់ ខែ ០៣ |
| ៦ | ដាក់លាន់ | លាន់ | ៦៥ | ខែ ០១ ដល់ ខែ ០២ |
| ៧ | កន្សំកំពឹស | ដុំ | ១០០ ដុំ | ខែ ០៧ ដល់ ខែ ០៣ |

### គ.២.ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុម សម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទមាត់ខ្លាមានសភាពប្រែប្រួលខ្លះ ដែលបណ្តាលមកពីកត្តាមនុស្ស និងធម្មជាតិ ដូចជាព្រៃកដែលធ្វើចរាចរទទួលនូវការរីងរាក់ដែលបណ្តាលមកពីការជាក់ក្នុងព្រែក និងការហូរច្រោះដោយសារការកាប់ទន្ទ្រានព្រៃលិចទឹកនៅតាមមាត់ព្រែក ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឲ្យសំបូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការស្តារលកពេជយំ | ១០ ហត | ១ ហត | ធ្វើការសិក្សា | ខែតុលា ២០១៩ | ខែធ្នូ ២០១៩ |
| | | | • ការស្តារព្រែក | ខែមករា ២០២០ | ខែធ្នូ ២០២០ |

### គ.៣ ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទមាត់ខ្លាបានសម្រេច ក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែង គឺ អន្លង់កោះពេជ្រយំ និងថ្លុលស្រោងដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទមាត់ខ្លា ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រក និងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេត ពិនិត្យរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិកសហគមន៍នសាទមាត់ខ្លា បានបញ្ជាក់ថា៖ កន្លែងអភិរក្សថ្លុលស្រោង និងអន្លង់កោះពេជ្រយំគឺជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្ស ដែលសមាជិកសហគមន៍នសាទមាត់ខ្លាមានសុឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្លូវស្រោង | ៩៦២ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • បោះបង្គោលស៊ីម៉ង់បន្ថែមចំនួន ៧ ដើម<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០១៨ |
| អន្លង់កោះពេជ្រយំ | ៥ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលស៊ីម៉ង់ចំនួន ៦ ដើម<br>• ផ្សព្វផ្សាយប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០១៩ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹកមានគ្របដណ្តប់លើដែននេសាទសហគមន៍មាត់ខ្លាមួយភាគធំ ដែលបាន ផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី សត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀត សម្រាប់ជាជម្រករស់នៅ បង្កកំណើតជាកូន និងជាចំណីផងដែរ។ ដូចនេះផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃលិចទឹកឲ្យនៅគង់វង្សយូរអង្វែងក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឱ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ បានកំណត់ និងបែងចែកនាទីព្រៃលិចទឹកមាន កន្លែងអភិរក្ស និងកន្លែងប្រើប្រាស់រំលោះ ដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ កន្លែងប្រើប្រាស់ព្រៃលិចទឹក ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឱ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ ។ ការកាប់រំលោះនេះ ធ្វើលក្ខណវិលជុំជារៀងរាល់បីឆ្នាំម្តង ដើម្បីទុកឲ្យព្រៃមានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន។

ដោយសារការយល់ដឹងពីសារៈសំខាន់នៃនាទីព្រៃលិចទឹក ប្រជាពលរដ្ឋមានការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង ។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍មាត់ខ្លាមានដូចជា៖

| ឈ្មោះ/ទីតាំង | ទំហំហត | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ដាំព្រៃលិចទឹកនៅកោះអញ្ចាញ | ៣ | រាំង ផ្ដោល ត្នួរ និងប្រកែង ។ល។ | • ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក | ១៥/១/១៧ | ១៨/១/១៨ |
| | | | • រៀបចំកូនឈើ | ១២/៥/១៧ | ៧/៦/១៨ |
| | | | • ពិធីដាំកូនឈើ និងដាក់ស្លាកសញ្ញាការពារ | ១០/៦/១៧ | ១៣/៦/១៨ |
| | | | • ថែរក្សា និងការពារ | ១៣/៦/១៧ | ៣០/៩/១៨ |
| ថែរក្សានិងការពារព្រៃលិចទឹក | ១២៣៤ | ព្រៃលិចទឹកគ្រប់ប្រភេទ | • ផ្សព្វផ្សាយផែនការ គ្រប់គ្រងព្រៃលិចទឹក | ៣/១/១៩ | ៥/១/១៩ |
| | | | • ដាក់ស្លាកសញ្ញាការពារ | ៥/៣/១៩ | ១០/៣/១៩ |
| | | | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

**គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគន៍មាត់ខ្លានេះ ។ ជាទូទៅប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីនៅតាមបែបដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ ត្រីប្រា និងត្រីអណ្ដែង។ល ។ ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចលក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឲ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៣២៥ ប្រក កសក ស្ដីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្ដោរ ដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូចនេះផងដែរ សហគមន៍នេសាទមាត់បានផ្ដោតសំខាន់លើការចិញ្ចឹមត្រីតាមបែបដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ ត្រីប្រា និងត្រី អណ្ដែង ពីព្រោះសហគមន៍នេះស្ថិតក្នុងតំបន់បឹងទន្លេសាប។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទមាត់ខ្លាក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទមាត់ខ្លា បានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីរ៉ស់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ ក្នុងបៃឬស្សីចំនួន ១៥គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបៃឬស្សីចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១៥ បៃ ទំហំ ៥ម X ៣ ម ត្រីរ៉ស | ត្រីរ៉ស់ | ៤,០០០ /គ្រួសារ | ១០/៦/១៧ | ៣០/៥/១៨ |
| ចិញ្ចឹមត្រីប្រាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ក្នុងបៃឬស្សីចំនួន ១០ គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបៃចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១០ បៃ ទំហំ ៥ម X ៣ ម ត្រីប្រា | | ៦,៥០០/ គ្រួសារ | ១២/៥/១៧ | ៣០/៦/១៨ |
| ចិញ្ចឹមត្រីអណ្តែងតាមបច្ចេកទេសជាលក្ខណៈគ្រួ សារក្នុងបៃឬស្សីចំនួន ៧ គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបៃចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ៧ បៃ ទំហំ ៥ម X ២,៥ ម ត្រីអណ្តែង | | ៤,០០០/ គ្រួសារ | ១២/៧/១៩ | ៥/១២/១៩ |

## គ.៦.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍បានដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ចំណូលពីក្រុមសន្សំប្រាក់១ក្រុម កន្លែងកំសាន្តធម្មជាតិ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ ។

ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍មានក្នុងតារាងខាងក្រោម៖

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូល(រៀល) |
|---|---|---|---|---|
| ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយនិងបណ្តុំភាគទាន | ២០១៧ | ២០១៩ | ១៩០.៥០០ |
| ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណភាគទាន | ២០១៧ | ២០១៩ | ៣.១២០.០០០ |
| សប្បុរសជននិងអង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុគរបរ<br>• ជាថវិកាផ្ទាល់ | ២០១៧ | ២០១៩ | ១០.០០០.០០០ |
| ក្រុមប្រឹក្សាឃុំ | ការពារធនធានធម្មជាតិ | ២០១៧ | ២០១៩ | ៩.០០០.០០០ |

## គ.៦ ផែនការផ្សេងៗទៀត

### គ.៦.១. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅ ដោយការកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
